ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
លេខ..........✓............ កកន

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលវេទិកាជាតិ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច ក្រោមប្រធានបទ «ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រី ដើម្បីទាំងអស់គ្នា»

កាលពីថ្ងៃសុក្រ ៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រសួងកិច្ចការនារីបានរៀបចំ**វេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច** ក្រោមប្រធានបទ **«ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រី ដើម្បីទាំងអស់គ្នា»** ក្នុងគោលបំណងលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រីនៅគ្រប់កម្រិតនិងគ្រប់ជំនាន់ ដើម្បីចូលរួមក្នុងកិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ ដូចបានចែងក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលបានចាត់ទុក **«ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ»** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាស្ត្រីមកពីព្រឹទ្ធសភា រដ្ឋសភា ក្រសួង-ស្ថាប័ន អង្គទូតនានា រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកសិក្សាស្រាវជ្រាវ ដៃគូពាក់ព័ន្ធ យុវជន និងវិស័យឯកជន **សរុបចំនួន២,៤៥០នាក់ (ចូលរួមផ្ទាល់ចំនួន៤២៨នាក់ និងតាមប្រព័ន្ធអនឡាញចំនួន២,០២២នាក់)**។

**វេទិកាជាតិឆ្នាំនេះ បានរំលេចនូវសកម្មភាពនិងលទ្ធផលគន្លឹះៗដូចខាងក្រោម៖**

នៅក្នុងកម្មវិធីបើកនៃវេទិកាជាតិ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍សំខាន់ៗដូចខាងក្រោម៖

១. បន្តរៀបចំបរិយាកាសអំណោយផលផ្នែកគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីឆ្លើយតបនានា ដើម្បីពន្លឿនការអនុវត្តសេចក្តីថ្លែងការណ៍និងផែនការសកម្មភាពទីក្រុងប៉េកាំង ព្រមទាំងរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិដែលមិនទុកអ្នកណាម្នាក់ឱ្យនៅឯកោ។ ការផ្លាស់ប្តូរជាប្រព័ន្ធដើម្បីជំរុញសមភាពក្នុងការទទួលបាន និងលទ្ធផលសម្រេចបានសម្រាប់ស្ត្រីនិងក្មេងស្រី។

២. រួមគ្នាអនុវត្តនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី៦និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យនៅគ្រប់កម្រិត ។

៣. ពង្រីកបរិយាកាសអំណោយផល មេត្រីភាព និងប្រកបដោយសុវត្ថិភាពនៅកន្លែងធ្វើការ នៅតាមសហគមន៍ និងទីសាធារណៈ ការដោះស្រាយបន្ទុកនៃការងារផ្ទះសម្បែង និងការងារថែទាំគ្មានប្រាក់កម្រៃសម្រាប់ស្ត្រីនិងក្មេងស្រី។

៤. បន្តរៀបចំនិងអនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីតាមរយៈការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ជំនាញបច្ចេកទេស ជំនាញទន់នានា និងភាពជាអ្នកដឹកនាំ រួមទាំងការលើកកម្ពស់សមត្ថភាពផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍ និងការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ប្រកបដោយសុវត្ថិភាព។



ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៧

៥. ពង្រីកយុទ្ធនាការសង្គមនិងជាសាធារណៈ ក្នុងការផ្លាស់ប្តូរឥរិយាបថនិងផ្នត់គំនិតអវិជ្ជមានរបស់សង្គម រួមទាំងលើកកម្ពស់ការចូលរួមគាំទ្រពីបុរសនិងក្មេងប្រុស។

៦. ស្ត្រីនិងក្មេងស្រីត្រូវតែកសាងជំនឿជឿជាក់លើខ្លួនឯង បណ្តុះភាពជាគម្រូនិងភាពជាអ្នកដឹកនាំដល់ស្ត្រីនិងក្មេងស្រីដទៃទៀត និងជំនាន់ក្រោយ ព្រមទាំងបង្កើនសំឡេង និងផ្តល់ការគាំទ្រគ្នាទៅវិញទៅមក។

នៅក្នុងរយៈពេលមួយថ្ងៃ អង្គវេទិកាជាតិបានពិភាក្សានិងពិគ្រោះយោបល់ដោយផ្តោតលើប្រធានបទសំខាន់ៗចំនួន៤ រួមមាន៖ ១. ព្រឹត្តិការណ៍អមស្តីពី **«ភាពជាអ្នកដឹកនាំអន្តរជំនាន់»**, ២. ព្រឹត្តិការណ៍អមស្តីពី **«ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងរបៀបវារៈនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ»**, ៣. ព្រឹត្តិការណ៍អមស្តីពី **«ការចែករំលែកបទពិសោធរបស់ក្មេងស្រីក្នុងភាពជាអ្នកដឹកនាំ»** និង៤. កិច្ចពិភាក្សាស្តីពី **«ការដាក់ចេញនូវវិធានការក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រី»** ។

**បញ្ហាប្រឈមដែលនៅសេសសល់ និងតម្រូវឱ្យបន្តដោះស្រាយរួមមាន៖**

- តម្រូវការការគាំទ្រពីក្រុមគ្រួសារ ក្នុងការចែករំលែកការទទួលខុសត្រូវលើបន្ទុកការងារផ្ទះ ការងារមើលថែទាំសមាជិកគ្រួសារនិងកូនៗ។
- ស្ត្រីនិងក្មេងស្រីមានតម្រូវការក្នុងការបង្កើនទំនុកចិត្តនិងភាពជឿជាក់លើខ្លួនឯង ព្រមទាំងសមត្ថភាពក្នុងការដឹកនាំ ការងារគ្រប់គ្រង ទំនាក់ទំនង ស្វែងរកការគាំទ្រមតិ និងការចរចា។
- កិច្ចសហការ និងការគាំទ្រពីសំណាក់សហការីនិងថ្នាក់ដឹកនាំផ្ទាល់ ដល់ស្ត្រីជាថ្នាក់ដឹកនាំឱ្យមានលទ្ធភាពបំពេញភារកិច្ចរបស់ខ្លួនក្នុងបរិយាកាសការងារអំណោយផល និងមានសុវត្ថិភាពដែលសម្រួលដល់ដំណើរការការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។
- បញ្ហាអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនៅតែបន្តកើតមាន ទាំងតាមបែបប្រពៃណី និងតាមរូបភាពថ្មីៗនៅលើប្រព័ន្ធអនឡាញ។
- ការរៀបការនៅវ័យក្មេង សុវត្ថិភាព និងការរំលោភបំពានដោយផ្ទាល់និងតាមអនឡាញលើស្ត្រីនិងក្មេងស្រី នៅតែបន្តកើតមាន។
- តម្រូវការបន្ថែមទៀតក្នុងការពង្រឹងនិងពង្រីកវិសាលភាព ក្នុងការអនុវត្តគោលនយោបាយ កម្មវិធី និងវិធានការពិសេស ក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅគ្រប់វិស័យ គ្រប់កម្រិត និងគ្រប់ជំនាន់។

**អនុសាសន៍ និងមតិយោបល់ទូទៅ៖**

- ពង្រីកការទទួលបានការអប់រំនិងវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ មានជាអាទិ៍៖ ការផ្តល់អាហារូបករណ៍។
- ពង្រឹងនិងពង្រីកកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ស្ត្រីនិងក្មេងស្រី រួមទាំងការហ្វឹកហាត់ និងការបណ្តុះភាពជាគំរូ តាមរយៈការបង្កើតបណ្តាញ/ក្លឹប ការហ្វឹកហាត់ដោយផ្សារភ្ជាប់រវាងស្ត្រីជាអ្នកដឹកនាំជាមួយនឹងក្មេងស្រីដែលមានសក្តានុពល។
- ចងក្រងនិងផ្សព្វផ្សាយនូវករណីសិក្សានិងឧត្តមានុវត្តរបស់ស្ត្រីឆ្នើម ដើម្បីផ្តល់ភាពជាគំរូនិងបង្កើនសន្ទុះចិត្ត។
- លើកកម្ពស់បរិយាកាសមេត្រីភាពនិងសុវត្ថិភាពនៅកន្លែងការងារ៖ ផ្តល់ការលើកទឹកចិត្តក្នុងការជ្រើសរើសប្រកបដោយបរិយាបន្ន និងលើកកម្ពស់គោលនយោបាយសេដ្ឋកិច្ចគិតគូរពីសុខុមាលភាពដូចជា ទារកដ្ឋាន បន្ទប់បំបៅដោះកូន ការរៀបចំពេលវេលាធ្វើការមានភាពបត់បែន ការឈប់សម្រាកលំហែមាតុភាព និងក្រមប្រតិបត្តិយេនឌ័រ។ល។

- ផ្តល់ភាពអង់អាចដល់ស្ត្រីនៅក្នុងអភិបាលកិច្ចមូលដ្ឋាន៖ គាំទ្រដល់ស្ត្រីជាថ្នាក់ដឹកនាំភូមិ ឃុំ សង្កាត់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងការអភិវឌ្ឍសមត្ថភាព ជំនាញបច្ចេកទេស ទំនុកចិត្ត ការធ្វើសេចក្តីសម្រេច និងភាពជាអ្នកដឹកនាំ។
- រៀបចំកម្មវិធីឬយុទ្ធនាការជាសាធារណៈ ដោយលើកកម្ពស់កិច្ចសន្ទនាអន្តរជំនាន់ រួមទាំងការគាំទ្រពីក្មេងប្រុសនិងបុរស ដើម្បីផ្លាស់ប្តូរនិយាមសង្គម និងគាំទ្រដល់ក្មេងស្រីនិងស្ត្រីដែលមានសក្តានុពលក្នុងការដឹកនាំ។
- លើកកម្ពស់ការប្រមូលទិន្នន័យនិងការតាមដាន៖ បង្កើតឧបករណ៍ដើម្បីតាមដានអំពីវឌ្ឍនភាព បញ្ហាប្រឈម និងទស្សនៈនៃការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រីនិងស្ត្រីដូចជាឧបករណ៍សន្ទស្សន៍ក្មេងស្រីដឹកនាំ ដើម្បីតាមដានអំពីវឌ្ឍនភាពនិងកំណត់បញ្ហាប្រឈម។
- លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រីនៅតាមវិស័យ ពិសេសនៅតាមសហគមន៍៖ រៀបចំកម្មវិធីភាពជាអ្នកដឹកនាំដែលរួមបញ្ចូលក្មេងស្រីនិងស្ត្រីនៅតាមវិស័យ។

នៅក្នុងពិធីបិទវេទិកាជាតិ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** បានបូកសរុបលទ្ធផលសំខាន់ៗ ដែលបញ្ជាក់ថា អង្គវេទិកាសំណូមពរឱ្យយកធាតុចូលនិងអនុសាសន៍ដែលទទួលបានពីវេទិកាថ្ងៃនេះ បញ្ចូលទៅក្នុងរបាយការណ៍ជូនទៅរាជរដ្ឋាភិបាល ព្រមទាំងចែករំលែកជាមួយក្រសួង-ស្ថាប័ន វិស័យឯកជន និងដៃគូពាក់ព័ន្ធ ដើម្បីជាធាតុចូលទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងដាក់ចេញនូវវិធានការជាក់លាក់ក្នុងការបន្តលើកកម្ពស់សមភាពយេនឌ័រ។ **«រួមគ្នាលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី មិនមែនត្រឹមតែជាគោលដៅតែប៉ុណ្ណោះទេ ប៉ុន្តែជាការបង្ហាញនូវការគោរពសិទ្ធិស្ត្រីនិងសិទ្ធិមនុស្ស, ការរួមបញ្ចូលនូវសក្តានុពលរបស់ពលរដ្ឋគ្រប់រូប, សមធម៌និងកំណើនសេដ្ឋកិច្ច និងជាការកសាងនូវដំណើរឆ្ពោះទៅការបង្កើតសង្គមដែលមានអារ្យធម៌ខ្ពស់»** ។

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥